**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ..[illegible]

ថ្ងៃចន្ទ ៧រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត**

**កម្មវត្ថុ៖** ការពង្រឹងការគ្រប់គ្រងចត្តាឡីស័ក ការអប់រំផ្សព្វផ្សាយនិងការអនុវត្តវិធានការសុខភាពសាធារណៈ និងបន្តការក្រើនរំលឹកណែនាំបន្ថែមអំពីការអនុវត្តវិធានការបង្ការការឆ្លងជាយថាហេតុនូវមេរោគកូវីដ-១៩ នៅតាមកន្លែងប្រកបអាជីវកម្មលក់ទំនិញ ឬផ្តល់សេវាកម្ម ដូចជា ផ្សារទំនើប ឱសថស្ថាន ហាងទំនិញ ធនាគារ សណ្ឋាគារ ភោជនីយដ្ឋាន ហាងកាត់សក់កែសម្ផស្ស និងសំអាងមុខ-កាយ កន្លែងលក់ដូរនៅក្នុងផ្សារនានា និងកន្លែងប្រកបអាជីវកម្មផ្សេងៗទៀត ដើម្បីកាត់ផ្តាច់ខ្សែចម្លងជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ទ្រង់ទ្រាយធំ។

**យោង៖** - ការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។**

- សេចក្តីណែនាំលេខ ២៤៩ សខល ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី-ខេត្តទាំងអស់**ជ្រាបថា ក្នុងពេលកន្លងមកនេះ ការងារទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ មានលទ្ធផលល្អប្រសើរគួរជាទីមោទនៈ។ ទោះជាយ៉ាងនេះក្តី "ព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា" គឺជាការឆ្លងមេរោគកូវីដ-១៩ ចូលក្នុងសហគមន៍ជាចង្កោម និងតាមកន្លែងមួយៗជាលើកទីមួយ ដែលមានហានិភ័យខ្ពស់គួរឱ្យបារម្ភសម្រាប់ប្រទេសកម្ពុជាយើង។ ដូច្នេះ ដើម្បីរួមគ្នាទប់ស្កាត់នូវការចម្លងក្នុងសហគមន៍ក្នុងទ្រង់ទ្រាយធំដែលនឹងអាចកើតមានឡើងក្នុងពេលណាមួយនោះ ខ្ញុំសូម **ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី-ខេត្តទាំងអស់** យកចិត្តទុកដាក់ខ្ពស់ជាបន្តទៀត ក្នុងការគ្រប់គ្រងអ្នកធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ និងការគ្រប់គ្រងអ្នកដំណើរចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាតាមច្រកដីគោក ទឹក និងអាកាស តាមច្រកអន្តរជាតិ និងតាមច្រករបៀងទាំងអស់ឱ្យបានហ្មត់ចត់ជាទីបំផុត ព្រមទាំងធ្វើការអប់រំផ្សព្វផ្សាយ និងចាត់វិធានការតាមដានការអនុវត្តវិធានការសុខាភិបាល ព្រមទាំងបន្តការក្រើនរំលឹកណែនាំអប់រំបន្ថែមអំពីការអនុវត្តវិធានការបង្ការការឆ្លងជាយថាហេតុនូវមេរោគកូវីដ-១៩ នៅតាមសហគមន៍ នៅតាមកន្លែងប្រកបអាជីវកម្មលក់ផលិតផល ឬផ្តល់សេវាកម្ម ដូចជា ផ្សារទំនើប កន្លែងឱសថស្ថាន ហាងទំនិញ ធនាគារ សណ្ឋាគារ ភោជនីយដ្ឋាន កន្លែងលក់ដូរនៅក្នុងផ្សារនានា និងកន្លែងប្រកបអាជីវកម្មផ្សេងៗ ដើម្បីកាត់ផ្តាច់ខ្សែចម្លងមេរោគកូវីដ-១៩ ឱ្យបានឆាប់បំផុត ដែលមានដូចតទៅ៖

១. ការគ្រប់គ្រងការធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ

- សូម ឯកឧត្តម លោកជំទាវ យកចិត្តទុកដាក់ខ្ពស់ជាបន្តទៀត ក្នុងការពង្រឹងវិធានការសំខាន់ៗនៃការធ្វើចត្តាឡីស័កតាមសណ្ឋាគារ តាមមណ្ឌលចត្តាឡីស័ក និងនៅតាមទីកន្លែងដែលកំណត់ដោយក្រសួងសុខាភិបាល (ក្នុងករណីចាំបាច់) រយៈពេល ១៤ថ្ងៃ ពេញលេញ សម្រាប់គ្រប់បុគ្គលដែលតម្រូវឱ្យមានការធ្វើចត្តាឡីស័ក។ ចំពោះអ្នកមកពីបរទេស គឺមិនមានការលើកលែង និងមិនអនុញ្ញាតឱ្យមានការធានាធ្វើចត្តាឡីស័កខ្លីសម្រាប់អ្នកធុរកិច្ចឡើយ ដោយត្រូវធ្វើចត្តាឡីស័កឲ្យបានគ្រប់ចំនួន ១៤ថ្ងៃ នៅតាមទីតាំងដែលបានកំណត់។ អាជ្ញាធរមូលដ្ឋាន ត្រូវគ្រប់គ្រងឱ្យបានហ្មត់ចត់ចំពោះការធ្វើចត្តាឡីស័កតាមផ្ទះ និងត្រូវផ្តត់ផ្គង់ប្រាក់ឧបត្ថម្ភសម្រាប់គ្រួសារដែលធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

ដែលបានឯកភាពប្រគល់ជូនអាជ្ញាធរថ្នាក់ក្រោមជាតិ ឱ្យទទួលខុសត្រូវតាមដាន និងគ្រប់គ្រងអ្នកធ្វើចត្តាឡីស័កនៅតាមមូលដ្ឋាន ក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

**២. ការអប់រំផ្សព្វផ្សាយ និងការអនុវត្តវិធានការសុខភាពសាធារណៈ**

- ជំរុញការអប់រំផ្សព្វផ្សាយឱ្យបានទូលំទូលាយក្នុងសហគមន៍នូវសារអប់រំសុខភាពរបស់ក្រសួងសុខាភិបាល តាមរយៈអាជ្ញាធរថ្នាក់ក្រោមជាតិ និងដោយមានការចូលរួមពីសហគមន៍ ដូចជាការផ្សព្វផ្សាយតាមរយៈឧបករណ៍បំពងសំឡេង ការបិទតាំងរូបភាពផ្ទាំងធំ ការចែកចាយខិតប័ណ្ណ ការផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ និងបណ្តាញសង្គមដល់ប្រជាជន ជាពិសេសដល់សហគមន៍ងាយរងគ្រោះ និងសហគមន៍ក្រីក្រជាដើម។
- ណែនាំ និងការចាត់វិធានការតាមដានការអនុវត្តវិធានការសុខាភិបាលនៅសហគមន៍ ដូចជាចាត់តាំងអាជ្ញាធរ ភូមិ ឃុំ ស្រុក សមាគមនារី និងតំណាងសហគមន៍ តាមមើល និងណែនាំការអនុវត្តគម្លាតសុវត្ថិភាពបុគ្គលពីម្នាក់ទៅម្នាក់ឱ្យបាន ១.៥ ម៉ែត្រ ឡើងទៅ នៅតាមទីតាំងសាធារណៈនានា។ ចាំបាច់ត្រូវអនុវត្តគម្លាតសុវត្ថិភាពសង្គមឱ្យបានហ្មត់ចត់ ដោយហាមឃាត់ ឬកាត់បន្ថយឱ្យបានជាអតិបរមា នូវការជួបជុំគ្នាក្នុងសង្គមដែលមានមនុស្សម្នាច្រើនលើសពីម្ភៃនាក់ ដូចជា ការរៀបអាពាហ៍ពិពាហ៍ ពិធីបុណ្យនានា មានដូចជាការជួបជុំគ្នា ក្នុងពិធីបុណ្យជាតិ ពិធីបុណ្យសាសនា ពិធីបុណ្យប្រពៃណី ឬពិធីបុណ្យផ្សេងៗ ការប្រគុំតន្ត្រី ការដើរលេងជួបជុំ បរិភោគអាហារជាមួយមិត្តភក្តិខាងក្រៅផ្ទះ ការជួបជុំពិធីខួបកំណើត ឬការធ្វើពិធីឡើងផ្ទះក្នុងទ្រង់ទ្រាយធំ ការធ្វើដំណើរកំសាន្តប្រមូលផ្តុំគ្នាច្រើន ជាដើម។
- ណែនាំ និងចាត់វិធានការជំរុញប្រជាជនក្នុងសហគមន៍ឱ្យយកចិត្តទុកដាក់រក្សាអនាម័យឲ្យបានស្អាតជានិច្ច ដោយលាងដៃជាមួយទឹកស្អាតនិងសាប៊ូ អាល់កុល ឬជែលលាងដៃ ឱ្យបានញឹកញាប់ ប្រើប្រាស់ម៉ាស់ឱ្យបានត្រឹមត្រូវជាប្រចាំ (ឬនៅក្នុងករណីចាំបាច់) ឬប្រើកន្សែង ក្រម៉ា ឬក្រដាសជូតមាត់ ដើម្បីខ្ទប់មាត់ និងច្រមុះពេលក្អក-កណ្តាស់។
- ណែនាំដល់អ្នកដែលមានហានិភ័យខ្ពស់នៃការចម្លងជំងឺ ដូចជាជនចាស់ជរា ជនដែលមានជំងឺប្រចាំកាយ ស្ត្រីមានផ្ទៃពោះ និងកុមារតូចៗជាដើម ជៀសវាងចេញពីផ្ទះ បើមិនចាំបាច់។

**៣. សូមបន្តធ្វើការក្រើនរំលឹក និងណែនាំបន្ថែមដោយជំរុញការអនុវត្តជាប់ជាប្រចាំ ជូនដល់ម្ចាស់អាជីវកម្ម អ្នកគ្រប់គ្រង បុគ្គលិក និងអតិថិជន នៅតាមកន្លែងប្រកបអាជីវកម្មលក់ទំនិញ ឬផ្តល់សេវាកម្ម ដូចជា ផ្សារទំនើប ឱសថស្ថាន ហាងទំនិញ ធនាគារ សណ្ឋាគារ ភោជនីយដ្ឋាន ហាងកាត់សក់ កែសម្ផស្ស និងសំអាងមុខ-កាយ កន្លែងលក់ដូរនៅក្នុងផ្សារនានា និងកន្លែងប្រកបអាជីវកម្មផ្សេងៗទៀត នូវវិធានការ "៣ កុំ " ដែលមានដូចខាងក្រោម៖**

- កុំ ទៅកន្លែងដែលបិទជិត គ្មានខ្យល់ចេញចូល ហើយប្រើម៉ាស៊ីនត្រជាក់ច្រើន (Avoid close settings)
- កុំ ទៅកន្លែងដែលមានមនុស្សម្នាច្រើនកុះករ ឬការជួបប្រជុំគ្នាច្រើន ឬពិធីដែលមានគ្នាច្រើន (Avoid crowded places)
- កុំ នៅជិត ឬខ្សឹបខ្សៀវ ឬប៉ះពាល់គ្នា ដោយត្រូវប្រើវិធីសំពះគ្នា លើកដៃជាសញ្ញា ឬងក់ក្បាល ឬឱនគ្នា ឬការពារដៃគ្នា ជាដើម (Avoid close contacts) ហើយត្រូវរក្សាចម្ងាយពីគ្នាមួយម៉ែត្រកន្លះឡើងទៅ

លើសពីនេះ គឺ៖

- ម្ចាស់អាជីវកម្ម គ្រប់បុគ្គលិកបម្រើការងារទាំងអស់គ្នាត្រូវពាក់ម៉ាស់ និងរបាំងមុខការពារឱ្យបានត្រឹមត្រូវ និងជាប់ជាប្រចាំ។
- អតិថិជនទាំងអស់ត្រូវពាក់ម៉ាស់វេជ្ជសាស្ត្រ ឬម៉ាស់ក្រណាត់ ឱ្យបានត្រឹមត្រូវ និងជាប់ជានិច្ចទាំងអស់គ្នា (លើកលែងពេលបរិភោគអាហារ)។
- កន្លែងប្រកបអាជីវកម្មលក់ផលិតផល ឬផ្តល់សេវាកម្មនានា ត្រូវ៖
    - បំពាក់ម៉ាស៊ីនវាស់កំដៅស្វ័យប្រវត្តិ ឬទែម៉ូម៉ែត្រវាស់កំដៅដោយដៃ និងអាល់កុល ឬជែលលាងដៃ នៅគ្រប់ច្រកចូល និងដាក់អាល់កុល ឬជែលលាងដៃនៅក្នុងទីតាំងប្រតិបត្តិការរបស់ខ្លួន និងតម្រូវឱ្យលាងដៃជាញឹកញាប់ជាពិសេសបន្ទាប់ពីបានប៉ះពាល់វត្ថុផ្សេងៗ ក្រោយពេលចូលបន្ទប់ទឹក និងមុនពេលបរិភោគអាហារ ជាដើម
    - ម្ចាស់អាជីវកម្ម អ្នកគ្រប់គ្រង និងបុគ្គលិកទាំងអស់ត្រូវលាងដៃជាមួយអាល់កុល ឬជែលលាងដៃឱ្យបានញឹកញាប់ យ៉ាងតិច ២០ដង ក្នុង១ថ្ងៃ (ឬច្រើនជាងតាមការចាំបាច់)
    - រៀបចំទីតាំងឈរ ឬអង្គុយសម្រាប់បុគ្គលិក និងអតិថិជនរបស់ខ្លួន ដោយរក្សាគម្លាតសុវត្ថិភាពយ៉ាងតិច ១.៥ ម៉ែត្រ ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់
    - ដាក់បង្ហាញនូវស្លាកសញ្ញាណែនាំការពាក់ម៉ាស់ និងរក្សាអនាម័យដៃស្អាត និងការណែនាំអនាម័យពេលក្អក-កណ្តាស នៅគ្រប់ច្រកចូល និងទីតាំងដែលអាចមើលឃើញទាំងអស់គ្នា

- ធ្វើការវាស់កំដៅបុគ្គលិករបស់ខ្លួនជារៀងរាល់ថ្ងៃ យ៉ាងតិច ៣ដង ក្នុង១ថ្ងៃ។

- ការធ្វើបដិសណ្ឋារកិច្ច ត្រូវធ្វើតាមទំនៀមទំលាប់ប្រពៃណីខ្មែរដោយលើកដៃសំពះចៀសវាងការចាប់ដៃគ្នា
- ម្ចាស់អាជីវកម្ម អ្នកគ្រប់គ្រង និងបុគ្គលិកបម្រើការងារទាំងអស់ត្រូវរាយការណ៍ឱ្យបានឆាប់រហ័សជូនដល់ អាជ្ញាធរពាក់ព័ន្ធ ឬក្រុមឆ្លើយតបបន្ទាន់តាមប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ ១១៥ ដោយមិនគិតថ្លៃ រាល់ពេលសង្កេតឃើញមានករណីសង្ស័យចូលក្នុងនិយមន័យនៃជំងឺកូវីដ-១៩
- អាជ្ញាធរពាក់ព័ន្ធទាំងអស់ត្រូវចាត់តាំងក្រុមការងារតាមដាន និងត្រួតពិនិត្យជាប់ជាប្រចាំ នូវការអនុវត្តវិធានការបង្ការការឆ្លងជាយថាហេតុនូវវីរុសកូវីដ-១៩ ដោយអាជីវករ និងអតិថិជនទាំងអស់ត្រូវពាក់ម៉ាស់មុនចូលហាងទំនិញ (គ្មានម៉ាស់ហាមចូល)
- ប្រសិនបើម្ចាស់អាជីវកម្ម អ្នកគ្រប់គ្រង និងបុគ្គលិកណាមិនគោរពអនុវត្តតាមវិធានការទាំងអស់ខាងលើបានហ្មត់ចត់ នឹងត្រូវផ្អាកអាជីវកម្មជាបណ្ដោះអាសន្នរហូតដល់មានការអនុញ្ញាតជាថ្មី។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ** មេត្តាអនុវត្តឱ្យបានម៉ឺងម៉ាត់ ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ឱ្យមានប្រសិទ្ធភាពខ្ពស់ និងកាត់ផ្តាច់ខ្សែចម្លងជំងឺកូវីដ-១៩ ឱ្យបានឆាប់បំផុត។

សូម ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**ម៉ម_ប៊ុនហេង**